**សម្រាប់ផ្សព្វផ្សាយបន្ទាន់**

## ប្រទេសនូវែលហ្សេឡង់ផ្ដល់ជំនួយសម្រាប់ការបោសសំអាតមីននៅកម្ពុជា

កិច្ចប្រជុំប្រចាំឆ្នាំនៃអនុសញ្ញាស្ដីពីការហាមប្រាមគ្រាប់មីនកំពុងប្រព្រឹត្តទៅនៅប្រទេសកម្ពុជា

(ភ្នំពេញ ថ្ងៃ ទី ២ ខែ ធ្នូ ឆ្នាំ ២០១១) យុទ្ធនាការប្រឆាំងគ្រាប់មីនរបស់នូវែលហ្សេឡង់ (CALM) សូមស្វាគមន៍សេចក្ដីសម្រេចចិត្តរបស់រដ្ឋាភិបាលនូវែលហ្សេឡង់ក្នុងការផ្ដល់ទឹកប្រាក់ចំនួន ១,០៥ លានដុល្លារអាមេរិក (១,៣ លានដុល្លារនូវែលហ្សេឡង់) ដើម្បីបោសសំអាតគ្រាប់មីននៅតំបន់ពាយ័ព្យនៃប្រទេសកម្ពុជា។ នូវែលហ្សេឡង់បានប្រកាសអំពីការរួមចំណែកក្នុងការផ្ដល់ជំនួយនៅថ្ងៃនេះនៅភ្នំពេញ ក្នុងកិច្ចប្រជុំប្រចាំឆ្នាំនៃរដ្ឋភាគីនៃអនុសញ្ញាហាមប្រាមគ្រាប់មីន ដែលបង្កើតឡើងនៅឆ្នាំ ១៩៩៧។

"នេះគឺជាការរួមចំណែកដ៏សំខាន់ និងទទួលបានការស្វាគមន៍បំផុតនៃមូលនិធិ ដែលនឹងជួយសង្គ្រោះជីវិត "នេះជាប្រសាសន៍របស់អ្នកស្រី Mary Wareham មន្ត្រីសម្របសម្រួលនៃយុទ្ធនាការ CALM ដែលកំពុងចូលរួមនៅក្នុងកិច្ចប្រជុំនៅភ្នំពេញ។ "កិច្ចប្រជុំនេះបានបញ្ជូនសារដ៏មានសារៈសំខាន់ អំពីការតាំងចិត្តរបស់ប្រទេសនូវែលហ្សេឡង់ ក្នុងការគាំទ្រនយោបាយរបស់ខ្លួនចំពោះការលុបបំបាត់ឱ្យអស់នូវអាវុធនេះ ដោយហិរញ្ញប្បទានដែលមានសារៈប្រយោជន៍"។

បណ្ឌិត Joan Mosley នាយកផ្នែករំសាយសព្វាវុធនៃក្រសួងការបរទេស និងពាណិជ្ជកម្ម នៃនូវែលហ្សេឡង់ បានប្រកាសថាវិភាគទាននៅក្នុងកិច្ចប្រជុំលើកទីដប់មួយនៃភាគីរដ្ឋនៃអនុសញ្ញាហាមប្រាមគ្រាប់មីន ជាកិច្ចប្រជុំការទូតចំបងមួយ កំពុងប្រព្រឹត្តទៅនៅភ្នំពេញ ប្រទេសកម្ពុជា ចាប់ពីថ្ងៃ ទី ២៧ ខែ វិច្ឆិកា រហូតដល់ថ្ងៃ ទី ២ ខែ ធ្នូ។ វិភាគទានដោះមីនរបស់ប្រទេសនូវែលហ្សេឡង់ គឺជាផ្នែកមួយនៃជំនួយដ៏ច្រើន ដែលមានទឹកប្រាក់ ២,៥ លាន ដុល្លារអាមេរិក (៣,២៧ លានដុល្លារនូវែលហ្សេឡង់) សម្រាប់គម្រោងអភិវឌ្ឍន៍កសិកម្មដែលមានរយៈពេល ៣ ឆ្នាំ នៅខេត្តឧត្តរមានជ័យ ដែលរងគ្រោះធ្ងន់ធ្ងរដោយ សារគ្រាប់មីន។ ការបោសសំអាតមីនក្រោមការផ្ដល់មូលនិធិដោយប្រទេសនូវែលហ្សេឡង់ នឹងត្រូវអនុវត្តដោយ Halo Trust ដែលជាអង្គការដោះមីនមួយរបស់ប្រទេសអង់គ្លេស។

កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមបណ្ដាប្រទេសនានា ដែលរងគ្រោះធ្ងន់ធ្ងរបំផុតដោយគ្រាប់មីន នៅលើពិភពលោក។ Landmine Monitor បានឱ្យដឹងថានៅកម្ពុជា មានអ្នកនៅរស់រានមានជីវិតពីគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រមាណជា ៤៤.០០០ នាក់។ កម្មវិធីសកម្មភាពមីនធំមួយ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩២ បានកាត់បន្ថយយ៉ាងច្រើននូវជនរងគ្រោះថ្មីដោយសារគ្រាប់មីន ប៉ុន្តែទោះជាយ៉ាងណាក្ដី ការបាត់បង់អាយុជីវិតនៅតែកើតមាន។ នៅឆ្នាំ ២០១០

នៅកម្ពុជា យ៉ាងហោចណាស់ មានជនរងគ្រោះពីគ្រាប់មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងពីសំណល់គ្រាប់បែកចង្កោមចំនួន ២៨៦ នាក់ដែរ។

តំណាងមកពីប្រទេសប្រហែល ១០០ រាប់ទាំងនូវែលហ្សេឡង់ផងដែរ កំពុងចូលរួមក្នុងកិច្ចប្រជុំលើកទី ១១ នៃរដ្ឋភាគី នៃអនុសញ្ញាហាមប្រាមគ្រាប់មីននៅភ្នំពេញ។ ប្រទេសសរុបចំនួន ១៥៨ បានចូលជារដ្ឋភាគីក្នុងអនុសញ្ញានេះ ហើយប្រទេសស៊ូដង់ខាងត្បូង ទើបបានចូលជារដ្ឋភាគី កាលពីថ្ងៃ ទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១១ នេះ។ អនុសញ្ញាស្ដីពីការហាមប្រាមគ្រាប់មីន ហាមឃាត់ទាំងស្រុងនូវមីនប្រឆាំងមនុស្ស ហើយតម្រូវឱ្យមានការបោសសំអាតមីនទាំងនេះ និងផ្ដល់ជំនួយដល់ជនរងគ្រោះ។ កិច្ចប្រជុំនេះកំពុងពិនិត្យមើលឡើងវិញនូវបញ្ហាអនុលោមភាពនៃអនុសញ្ញា រាប់ទាំងការគម្រាមកំហែងចំពោះនិយាមថ្មី ចំពោះការប្រើប្រាស់គ្រាប់មីនថ្មី នៅតាមបណ្ដាប្រទេសនានា រួមមាន អ៊ីស្រាអែល លីប៊ី និងមីយ៉ាន់ម៉ា (ភូមា)។

CALM កំពុងផ្ដល់ជំនួយឥតសំណងចំនួន ១.២០០ ដុល្លារអាមេរិក ទៅឱ្យអង្គការ Jesuit Service Cambodia ដែលនឹងយកទៅប្រើសម្រាប់សាងសង់ផ្ទះសម្បែងសម្រាប់អ្នកនៅរស់រានមានជីវិតពីគ្រាប់មីន និងសម្រាប់បរិធានចល័ត ដូចជារទេះជនពិការ ជាដើម។ អំណោយនេះ រួមមាន មូលនិធិបានមកពីការដេញថ្លៃរបស់សិប្បកម្ម Trade Me តាមអ៊ិនធើណិតនូវកាបូបដែលផលិតដោយវត្ថុធាតុដើមក្នុងស្រុក ផលិតដោយស្ត្រីដែលនៅរស់រានមានជីវិតពីគ្រាប់មីន នៅខេត្តកណ្ដាលនៃប្រទេសកម្ពុជា។

នៅខែ តុលា ឆ្នាំ ២០១១ ឯ.ឧ. McCully រដ្ឋមន្ត្រីការបរទេស នូវែលហ្សេឡង់ បានបញ្ជាក់ថា នូវែលហ្សេឡង់កំពុងផ្ដល់ទឹកប្រាក់សរុបចំនួន ២.៨ លានដុល្លារ សម្រាប់គម្រោងបោសសំអាតមីននៅ West Bank (ទឹកដីប៉ាឡេស្ទីនដែលត្រូវបានកាន់កាប់)។ ឯ.ឧ. McCully ក៏បានបញ្ជាក់ថា ជំនួយរយៈពេលវែងរបស់បុគ្គលិកយោធានៃកងទ័ពនូវែលហ្សេឡង់ ដែលបម្រើសេវាសកម្មភាពមីនរបស់អង្គការសហប្រជាជាតិ (UNMAS) នៅញូវយ៉ក ត្រូវបានបញ្ចប់នៅឆ្នាំ ២០១១។

CALM គឺជាសមាជិកដែលមានចំណាស់នៃយុទ្ធនាការអន្តរជាតិចំពោះការហាមប្រាមគ្រាប់មីន (ICBL) ជាជ័យលាភីណូបែលស្ដីពីសន្តិភាពនៅឆ្នាំ ១៩៩៧ និងជាយុទ្ធនាការរបស់ដូនជីចំពោះសម្ព័ន្ធគ្រាប់បែកចង្កោមនូវែលហ្សេឡង់នៅ Aotearoa (ANZCMC)។ CALM និង ANZCMC ត្រូវបានគ្រប់គ្រងរួមគ្នា ដោយក្រុមការងារដែលមានសមាសភាពក្រុម ដូចតទៅ: Amnesty International Aotearoa NZ, Caritas Aotearoa NZ, Christian World Service, Engineers for Social Responsibility, International Physicians for the Prevention of Nuclear War NZ, National Council of Women NZ, National Consultative Committee on Disarmament, Oxfam NZ, Peace Movement Aotearoa, Soroptimist International NZ, United Nations Association NZ, United Nations Youth Association NZ, UNICEF NZ, និង Women's International League for Peace and Freedom, Aotearoa.

ចំពោះព័ត៌មានបន្ថែម សូមទាក់ទងអ្នកស្រី Mary Wareham មន្ត្រីសម្របសម្រួលយុទ្ធនាការ CALM។ ទូរស័ព្ទ (០២១) ៩៩៦-៩០៥ ឬ +៨៥៥ (៩៥) ៩៨២-៨៦២

ចំពោះព័ត៌មានបន្ថែម សូមអាន៖

គេហទំព័រ CALM-www.calm.org.nz

Landmine Monitor 2011 Cambodia – http://bit.ly/ralBLU
11 MSP website – http://bit.ly/spxxO8